CITY OF LONG BEACH **PRESS RELEASE**

**សេចក្តីប្រកាសពត៌មាន**

ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ ២០២០

ទំនាក់ទំនង: នាយកដ្ឋានពន្លត់អគ្គីភ័យឡុងប៊ីឆ ហាតឡាញបង្ករអគ្គីភ័យ លេខ (562) 570-2582

# រង្វាន់ $20,000 សម្រាប់ព័ត៌មានស្តីពីការបង្ករអគ្គីភ័យ ឬការដុតហាងលក់សំលៀកបំពាក់ឈុតរបស់បុរស (Men’s Suit Outlet Store) នៅក្រុងឡុងប៊ីឆ

ក្រុងឡុងប៊ីឆ, រដ្ឋកាលីហ្វ័រញ៉ា — ទឹកប្រាក់សរុប $20,000 ត្រូវបានផ្តល់ជូនជារង្វាន់សម្រាប់ព័ត៌មានដែលឈានទៅដល់ការកំណត់អត្តសញ្ញាណ និងការចាប់ខ្លួនអ្នកដែលទទួលខុសត្រូវចំពោះការបង្ករ ឬដុតអគ្គីភ័យជាច្រើន ដែលបានបំផ្លាញអាជីវកម្មជាច្រើននៅក្នុងឡុងប៊ីឆ។ ទីក្រុងឡុងប៊ីឆបានចូលរួមវិភាគទានចំនួន $10,000 ហើយការិយាល័យគ្រឿងស្រវឹង, ថ្នាំជក់, អាវុធ និងគ្រឿងផ្ទុះ (ATF) បានបរិច្ចាគថវិការដំបូង ចំនួន $10,000។

អភិបាលក្រុង Robert Garcia មានប្រសាសន៍ថា “យើងបានធ្វើការប្តេជ្ញាចិត្ត ជួយដល់អាជីវកម្មនានាដែលត្រូវបានបំផ្លាញ ក្នុងការកសាងឡើងវិញ”។ “ក្នុងនាមជាទីក្រុង, យើងនឹងបន្តធ្វើការកំណត់អត្តសញ្ញាណអ្នកទទួលខុសត្រូវចំពោះបញ្ហានេះ ដើម្បីអោយយើងអាចធ្វើសកម្មភាពបាន, ហើយយើងត្រូវការជំនួយរបស់សហគមន៍”។

ការចំណាយ $10,000 របស់ទីក្រុង សម្រាប់រង្វាន់នេះ ត្រូវបានអនុម័តជាឯកច្ឆ័ន្ទដោយក្រុមប្រឹក្សាក្រុងកាលពីថ្ងៃទី ៧ ខែកក្កដា ឆ្នាំ ២០២០។

អគ្គិភ័យមួយ នៃអគ្គីភ័យជាច្រើន បានចាប់ផ្តើមនៅម៉ោងប្រហែល ១០ យប់ នៅថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០២០ នៅហាងឈុតបុរស ដែលមានទីតាំងនៅផ្ទះលេខ 655 Pine Ave., ក្នុងអំឡុងពេលនៃភាពចលាចលស៊ីវិល។ ភ័ស្តុតាងវីដេអូបង្ហាញនូវជនសង្ស័យជាច្រើននាក់ បានចូលមកកាន់ហាងអាជីវកម្ម

ហើយបោះនូវឧបករណ៍ដែលអាចបញ្ឆេះភ្លើង ចំនួនពីរ (ជាទូទៅគេហៅថា ស្រាក្រឡុក Molotov) នៅខាងក្នុងអាជីវកម្ម។ អគ្គីភ័យជាបន្តបន្ទាប់គ្នា បានបំផ្លាញអគារ និងអាជីវកម្មចំនួន ៥ ដែលកំពុងប្រតិបត្តិការ ចេញពីអគារ។ ការខាតបង់ដោយសារតែអគ្គីភ័យនេះតែមួយមុខ ត្រូវបានប៉ាន់ប្រមាណថា មានចំនួន $5,176,200។

ភ័ស្តុតាងវីឌីអូបង្ហាញនូវជនសង្ស័យមិនស្គាល់អត្តសញ្ញាណដូចគ្នាទាំងនេះ បោះនូវឧបករណ៍ដែលអាចបញ្ឆេះភ្លើងជាច្រើន និងបំផ្លាញក្រុមហ៊ុន Pacific Travel Insurance and Income Tax ដែលមានទីតាំងស្ថិតនៅផ្ទះលេខ 951 Pine Avenue, ក៏ដូចជា Burger King, ដែលមានទីតាំងនៅផ្ទះលេខ 127 W. 4th St.។

ការស៊ើបអង្កេតនេះ ត្រូវបានធ្វើឡើងរួមគ្នាដោយនាយកដ្ឋានពន្លត់អគ្គីភ័យនៅឡុងប៊ីឆ និងផ្នែក ATF Los Angeles Field Division។ រូបភាពវីឌីអូ របស់ជនសង្ស័យទាំងឡាយ អាចរកឃើញតាម អ៊ីនធឺណិត។ អ្នកណាម្នាក់ ដែលមានព័ត៌មានទាក់ទងអំពីជនសង្ស័យដែលមិនត្រូវបានគេស្គាល់អត្តសញ្ញាណទាំងនេះ ឬព័ត៌មានអំពីអគ្គិភ័យដែលបានរាយខាងលើ ត្រូវបានលើកទឹកចិត្តអោយទាក់ទង មកកាន់ការិយាល័យពន្លត់អគ្គីភ័យឡុងប៊ីឆ ហតឡាញបង្ករអគ្គីភ័យ លេខ (562) 570-2582។

ភ្ជាប់មកជាមួយនេះ គឺជារូបថតនៃជនសង្ស័យនានា ដែលបានបោះនូវឧបករណ៍ដែលអាចបញ្ឆេះភ្លើងចូលទៅក្នុងហាងសំលៀកបំពាក់ឈុតរបស់បុរស នៅឡុងប៊ីឆ, កាលពីថ្ងៃទី ៣១ ខែឧសភា, ដែលបំផ្លាញហាង និងអាជីវកម្មជាច្រើន ដែលនៅជាប់ៗគ្នានោះ។

CITY OF LONG BEACH

# PRESS RELEASE





**អំពីទីក្រុងឡុងប៊ីឆ**

ទីក្រុងឡុងប៊ីឆ មានប្រជាជនប្រមាណ ៤៧០,០០០ នាក់, ជាទីក្រុងដែលទទួលបានពានរង្វាន់យ៉ាងច្រើន និងទីក្រុងប្រកបដោយភាពច្នៃប្រឌិត ផ្តល់ជូននូវភាពឆើតឆាយ ជាទីមនោរម្យសំបូរបែប លំដាប់ពិភពលោកនៃទីក្រុងប្រជុំជនដ៏ធំមួយ ក្នុងខណៈពេលដែលរក្សាបាននូវអារម្មណ៍ដ៏រឹងមាំនៃឯកត្តបុគ្គល និងសង្កាត់ផ្សេងៗ ដែលបានរស់នៅផ្តុំគ្នាយ៉ាងសុខស្រួល នៅតាមបណ្តោយឆ្នេរសមុទ្រកាលីហ្វ័រញ៉ា។ ក្នុងនាមជាទីក្រុងដែលមានសេវាកម្មពេញលេញ, ទីក្រុងឡុងប៊ីឆ ជាផ្ទះរបស់ម្ចាស់ក្សត្រី Queen Mary, អាងចិញ្ចឹមត្រី នៃមហាសមុទ្រប៉ាស៊ីហ្វិក, សារៈមន្ទីរ និងរោងកុន ជាច្រើន, សាលារៀនស្តូលឌីសទ្រីច ដែលត្រូវបានវាយតម្លៃយ៉ាងខ្ពស់, អាកាសយានដ្ឋានឡុងប៊ីឆ និងកំពង់ផែឡុងប៊ីឆ។ ផងដែរ ទីក្រុងនេះក៏មានសាកលវិទ្យាល័យ និងមហាវិទ្យាល័យ ដែលត្រូវបានគេគោរពខ្ពស់, កន្លែងចិញ្ចឹមសត្វជាប្រវត្តិសាស្ត្រពីរ, មន្ទីរពេទ្យចំនួនប្រាំ, ទីលានវាយកូនហ្គោលចំនួនប្រាំ, សួនឧទ្យានចំនួន ១៧១, ឆ្នេរខ្សាច់ជាច្រើនម៉ាយល៍, កំពង់ផែ ឬម៉ារីណា និងផ្លូវជិះកង់។

CITY OF LONGBEACH

# PRESS RELEASE

សម្រាប់ព័ត៌មានបន្ថែម អំពីទីក្រុងឡុងប៊ីឆ, ទស្សនា http://longbeach.gov/. តាមពួកយើង នៅលើបណ្តាញសង្គម ដើម្បីតាមដាន ឬទទួលបាននូវព័ត៌មានថ្មីៗ: Facebook, Twitter, Instagram និង YouTube.

###